**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**ក្រសួងមហាផ្ទៃ**
**គម្រោង ធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និង**
**សំណល់ប្លាស្ទិកនៅប្រទេសកម្ពុជា**
**IDA Grant No. 7292-KH**

# លក្ខខណ្ឌការងារសម្រាប់អ្នកបើកបរ

**មុខដំណែង** : អ្នកបើកបរ
**ទីកន្លែង** : ក្រសួងមហាផ្ទៃ
**រយៈពេល** : ១២ខែ (អាចបន្តផ្អែកតាមការវាយតម្លៃលើលទ្ធផលនៃការអនុវត្តការងារប្រចាំឆ្នាំ)

១. រាជរដ្ឋាភិបាលកម្ពុជាបានទទួលឥណទាន សម្បទានពីធនាគារពិភពលោក(IDA Grant No. 7292) សម្រាប់អនុវត្តគម្រោងការធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅកម្ពុជា សម្រាប់រយៈពេល ៦ឆ្នាំ (២០២៣ ដល់ ២០២៩) មានថវិកាសរុប ៦៧,៣ លានដុល្លាអាមេរិកដែលចែកជាបីសមាសភាគ។ ក្រសួងមហាផ្ទៃជាភ្នាក់ងារប្រតិបត្តិគម្រោងសមាសភាគទី២ ដែលមាន ថវិកា៨,៤២លានដុល្លាអាមេរិក។

២. គម្រោងការធ្វើឱ្យប្រសើរឡើងនៃការគ្រប់គ្រងសំរាម សំណល់រឹង និងសំណល់ប្លាស្ទិកនៅកម្ពុជានៃ ក្រសួងមហាផ្ទៃ នឹងត្រូវជ្រើសរើសអ្នកបើកបរ ចំនួន ០៣នាក់ ក្នុងគោលបំណងទទួលខុសត្រូវលើការងារសំខាន់ដែលរួមមាន ទី១-បើកបរជូនថ្នាក់ដឹកនាំ និងមន្រ្តីគម្រោង ដើម្បីចុះបំពេញការងារ ទី២-ថែទាំ និងគ្រប់គ្រងយានយន្តឱ្យបានត្រឹមត្រូវតាមបច្ចេកទេសត្រឹមត្រូវ ទី៣-ជួយការងាររដ្ឋបាលក្នុងការយកលិខិតនានា ទៅចែកជូនក្រសួងស្ថាប័ន ភ្នាក់ងារអនុវត្តគម្រោង និងអ្នកពាក់ព័ន្ធនានា។

**ក. បេក្ខជនត្រូវមានលក្ខណសម្បត្តិដូចខាងក្រោម ៖**

- ជាជនជាតិខ្មែរ
- មានកម្រិតសិក្សាចាប់ពីថ្នាក់ទី១២
- មានអាយុចាប់ពី១៨ឆ្នាំ ដល់៥៥ឆ្នាំ
- មានបទពិសោធន៍បើកបររថយន្ត(លេខដៃ និងលេខអូតូ)យ៉ាងតិច០៥ឆ្នាំ មានបណ្ណបើកបរដែលមានសុពលភាព និងស្របច្បាប់
- យល់ដឹងពីច្បាប់ចរាចរណ៍ និងចេះថែទាំជួសជុលរថយន្តខ្លះៗ
- មានកាយសម្បទា និងសុខភាពល្អ និងអាចចុះធ្វើការតាមខេត្តនានាបាន
- មានភាពស្មោះត្រង់ សុភាពរាបសារ គោរពវិន័យ វិជ្ជាជីវៈ និងមិនធ្លាប់មានទោស ឬជាប់ក្នុងបទឧក្រិដ្ឋ
- ឧស្សាហ៍ព្យាយាម និងអំណត់ក្នុងការងារ
- អាចអាន និងសរសេរភាសាអង់គ្លេសបានកាន់តែប្រសើរ។

**ខ. ភារកិច្ច និងការទទួលខុសត្រូវ ៖**

- ត្រូវធានាឱ្យបាននូវសុវត្ថិភាពក្នុងការបើកបរ និងថែទាំរថយន្តឱ្យបានត្រឹមត្រូវតាមបទដ្ឋានបច្ចេកទេស
- ត្រូវត្រួតពិនិត្យលក្ខណៈបច្ចេកទេសរថយន្ត និងសម្អាតរថយន្តរៀងរាល់មុនពេលចេញដំណើរចុះបំពេញបេសកកម្ម និងត្រឡប់មកវិញ
- ត្រូវកត់ត្រាសកម្មភាពបើកបរ និងការងារប្រចាំថ្ងៃចូលក្នុងសៀវភៅតាមដានការប្រើប្រាស់រថយន្ត
- ត្រូវរាយការណ៍ដោយស្មោះត្រង់ និងឆាប់បំផុតនូវរាល់បញ្ហា ឬបាតុភាពផ្សេងៗក្នុងពេលបើកបរ
- ត្រូវទទួលខុសត្រូវចំពោះមុខច្បាប់ជាធរមាននូវរាល់កំហុសឆ្គង និងការបង្កគ្រោះថ្នាក់ចរាចរណ៍ដែលកើតឡើងពីការធ្វេសប្រហែស ឬការរំលោភបំពានច្បាប់ចរាចរណ៍
- ត្រូវបំពេញភារកិច្ចចាំបាច់ផ្សេងៗទៀត។

៣. បេក្ខជនដែលមានលក្ខណៈសម្បត្តិសមស្របនឹងត្រូវបានសម្រាំង និងទទួលបានការសម្ភាសន៍ស្ទង់សមត្ថភាព មុននឹងត្រូវបានសម្រេចឱ្យចូលបម្រើការងារជាបុគ្គលិកជាប់កិច្ចសន្យា។

៤. បេក្ខជនដែលមានចំណាប់អារម្មណ៍សម្រាប់មុខតំណែងខាងលើនេះ អាចទំនាក់ទំនងសាកសួរព័ត៌មាន និងដាក់ពាក្យមកអាសយដ្ឋាន ដូចខាងក្រោម៖ ក្រសួងមហាផ្ទៃ បន្ទប់លេខ ៣៥៦ ជាន់ទី ៣ មហាវិថី ព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ ឬតាមសារអេឡិចត្រូនិច dst.samreth@gmail.com និងទូរសព្ទលេខ ០១២ ៣៧៦ ១៧៥